**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

ភ្នំពេញ ថ្ងៃទី០៩ ខែ កក្កដា ឆ្នាំ២០០៨

# សេចក្តីថ្លែងការណ៍
# របស់អ្នកនាំពាក្យ គ.ជ.ប

ថ្មីៗនេះមានលេចឮព័ត៌មានឃោសនាថា អ្នកដែលគ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត មិនអាចបោះឆ្នោតបាន និងថា មានអ្នកដើរប្រមូលប័ណ្ណព័ត៌មានពីអ្នកបោះឆ្នោតដែលត្រូវបានគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត រួមជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងមេភូមិ ចែកជូនរួចហើយ ។

ការផ្សព្វផ្សាយនូវព័ត៌មានមិនពិត និងសកម្មភាពដូចខាងលើនេះ គឺជាការរារាំងដល់ដំណើរការរៀបចំការបោះឆ្នោត ។ គ.ជ.ប សូមអំពាវនាវឱ្យបញ្ឈប់ជាបន្ទាន់នូវសកម្មភាពខុសច្បាប់ទាំងនេះ ។ គ.ជ.ប សូមណែនាំមន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ រួមសហការជាមួយអាជ្ញាធរដែនដី ដើម្បីទប់ស្កាត់នូវសកម្មភាពរារាំងការបោះឆ្នោតនេះ ។ ម្យ៉ាងទៀត គ.ជ.ប សូមប្រជាពលរដ្ឋទាំងអស់មេត្តាជួយផ្តល់ព័ត៌មានមកមន្ត្រីបោះឆ្នោត ឬអាជ្ញាធរមានសមត្ថកិច្ច ដើម្បីរកមុខរកជនល្មើសយកមកផ្តន្ទាទោសតាមច្បាប់ ។

គ.ជ.ប សូមរំលឹកឡើងវិញថា ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតគ្រាន់តែជាព័ត៌មានជូនអ្នកបោះឆ្នោតឱ្យដឹងអំពី÷

- ថ្ងៃបោះឆ្នោត គឺនៅថ្ងៃអាទិត្យ ទី២៧ ខែកក្កដា ឆ្នាំ២០០៨ ចាប់ពីម៉ោង ៧:០០ព្រឹក ដល់ម៉ោង ៣:០០រសៀល ។
- លេខរៀង ឈ្មោះ ភេទ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើតរបស់អ្នកបោះឆ្នោត ។
- ទីតាំង និងលេខកូដការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលត្រូវទៅបោះឆ្នោត ។
- ប្រភេទឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយ ដែលអាចប្រើប្រាស់នៅពេលបោះឆ្នោត ។

ម្យ៉ាងទៀត មានប័ណ្ណព័ត៌មានក្នុងពេលបោះឆ្នោត នាំឱ្យមានការងាយស្រួលក្នុងការរកឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតឱ្យបានឆាប់ មិនឱ្យអ្នកបោះឆ្នោតរង់ចាំយូរ ។

គ.ជ.ប សូមបញ្ជាក់ផងដែរថា ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនេះ មិនអាចប្រើជំនួសឯកសារបញ្ជាក់អត្តសញ្ញាណរបស់សាមីខ្លួននៅពេលបោះឆ្នោតបានឡើយ ហើយគ្មានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត បងប្អូនក៏បោះឆ្នោតបានដែរ ។

ដូច្នេះសូមបងប្អូនប្រជាពលរដ្ឋទាំងអស់ កុំជឿតាមព័ត៌មានអកុសលខាងលើនេះឱ្យសោះ ។ ទន្ទឹមនឹងនេះ ប្រសិនបើប្រជាពលរដ្ឋណាដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ហើយមិនទាន់បានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនេះទេ សូមអញ្ជើញទៅទទួលយកនៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ដែលមានទីតាំងក្នុងឃុំ សង្កាត់ដែលបងប្អូនកំពុងរស់នៅ ចាប់ពីថ្ងៃនេះ រហូតដល់ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០០៨ វេលាម៉ោង ៥:៣០នាទីល្ងាច ។